**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលកិច្ចប្រជុំលើកទី៥ នៃគណៈកម្មការចម្រុះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឥណ្ឌូណេស៊ី

**ឯកឧត្តម សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើជាសហប្រធានអង្គប្រជុំជាមួយ **លោកជំទាវ** Retno L.P. Marsudi រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដឹកនាំកិច្ចប្រជុំលើកទី៥ នៃគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី (JCBC) កម្ពុជា-ឥណ្ឌូណេស៊ី នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ភាគីទាំងពីរបានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាពជារួមក្នុងវិស័យនានាចាប់តាំងពីកិច្ចប្រជុំ JCBC កម្ពុជា-ឥណ្ឌូណេស៊ី លើកចុងក្រោយ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី។

ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការនយោបាយ ភាគីទាំងពីរបានអបអរសាទរចំពោះសកម្មភាពរួមគ្នានានាជាច្រើន ដែលរៀបចំឡើងដើម្បីរំលឹកខួបលើកទី៦៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងឥណ្ឌូណេស៊ី នាឆ្នាំនេះ។

**រដ្ឋមន្ត្រីទាំងពីរ** បានសង្កត់ធ្ងន់លើសារសំខាន់នៃការរក្សា និងលើកកម្ពស់ការប្រាស្រ័យទាក់ទងគ្នាជាញឹកញាប់រវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ នៅគ្រប់លំដាប់ថ្នាក់ និងបានគូសបញ្ជាក់ពីសារសំខាន់ជាយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងក្នុងចំណោមថ្នាក់ដឹកនាំកំពូល រួមទាំងជំនួបនាពេលថ្មីៗចំនួន២លើក រវាង **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** និង **ឯកឧត្តមប្រធានាធិបតី ចូកូ វីដូដូ** នៅទីក្រុងហ្សាការតា នៅឆ្នាំ២០២៣ និងនៅ ទីក្រុងម៉ែលបិន នៅឆ្នាំនេះ។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 1[illegible]2
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការសន្តិសុខ និងការពារជាតិ រដ្ឋមន្ត្រីទាំងពីរបានវាយតម្លៃខ្ពស់ និងឯកភាពបន្តធ្វើការប្រាស្រ័យទាក់ទងប្រកបដោយផ្លែផ្កា រួមមានកិច្ចពិភាក្សារវាងកងទ័ពជើងគោក អាហារូបករណ៍ និងការបណ្តុះបណ្តាល និងសកម្មភាពការផ្លាស់ប្តូរផ្សេងទៀត ដូចជាការចូលសំចតនាពេលថ្មីៗនេះរបស់នាវាហ្វឹកហ្វឺនកងទ័ពជើងទឹកឥណ្ឌូណេស៊ី KRI Bima Suci ដែលមាននាវិកចំនួន ២១២នាក់ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤។ **រដ្ឋមន្ត្រីទាំងពីរ** បានបញ្ជាក់ការប្តេជ្ញាចិត្តឡើងវិញដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការល្អដែលមានស្រាប់ ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសការជួញដូរមនុស្ស ដោយត្រូវអនុវត្តយ៉ាងពេញលេញនិងមានប្រសិទ្ធភាពនូវលិខិតុបករណ៍ពាក់ព័ន្ធ ក្រោមក្របខ័ណ្ឌទ្វេភាគី និងអាស៊ាន។

លើវិស័យសេដ្ឋកិច្ច **រដ្ឋមន្ត្រីទាំងពីរ** កត់សម្គាល់ដោយការពេញចិត្តចំពោះការបន្តកើនឡើងនៃទំហំពាណិជ្ជកម្មទ្វេភាគីដែលបានកើនឡើងដល់លើស ១ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ និងបានឯកភាពពន្លឿនការពិភាក្សាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីពាណិជ្ជកម្មអង្ករ។ **រដ្ឋមន្ត្រីទាំងពីរ** បានគូសបញ្ជាក់ពីសារសំខាន់នៃសន្តិសុខស្បៀង និងបានអះអាងពីការប្តេជ្ញាចិត្តក្នុងការពន្លឿនការអនុវត្ត MoU ស្តីពីកិច្ចសហប្រតិបត្តិការកសិកម្ម ដែលបានចុះហត្ថលេខានៅខែកញ្ញា ឆ្នាំ២០២៣ និងការចុះហត្ថលេខាលើ MoU ស្តីពីកិច្ចសហប្រតិបត្តិការសហគ្រាសធុនតូច និងមធ្យម។

ក្នុងគោលបំណងពង្រឹងការតភ្ជាប់ និងសម្រួលការផ្លាស់ប្តូរសេដ្ឋកិច្ច និងវប្បធម៌ ភាគីទាំងពីរបានឯកភាពជំរុញឱ្យមានជើងហោះហើរត្រង់បន្ថែមទៀតរវាងទីក្រុងទេសចរណ៍នៃប្រទេសទាំងពីរ បញ្ចប់ការពិភាក្សា MoU ស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌ បន្តឡើងវិញនូវកិច្ចសហប្រតិបត្តិការសម្ព័ន្ធមេត្រីភាពរវាងខេត្តសៀមរាប និងខេត្តជ្វាកណ្តាល និងបង្កើតទំនាក់ទំនងខេត្ត-ក្រុងសម្ព័ន្ធមេត្រីភាព រវាងរាជធានីភ្នំពេញ និងកោះស៊ូម៉ាត្រាខាងលិច។

កិច្ចប្រជុំបានឯកភាពគ្នាក្នុងការពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងវិនិយោគឥណ្ឌូណេស៊ី។ កិច្ចប្រជុំក៏បានស្វាគមន៍គោលបំណងរបស់ក្រុមហ៊ុនឥណ្ឌូណេស៊ី Perum BULOG ក្នុងការវិនិយោគនៅកម្ពុជាលើវិស័យកសិកម្ម ដូចជាម៉ាស៊ីនកិនស្រូវ និងឃ្លាំង។

កិច្ចប្រជុំបានពិភាក្សាយ៉ាងទូលំទូលាយអំពីកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗផ្សេងទៀត រួមមាន ថាមពល, បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT), សុខាភិបាល, ការគ្រប់គ្រងអាងទន្លេ, បរិវត្តកម្មឌីជីថល, និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ដោយមានទស្សនៈដូចគ្នាពីសារសំខាន់នៃសន្តិភាពសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច **រដ្ឋមន្ត្រីទាំងពីរ** បានពិភាក្សាលើបញ្ហាតំបន់ និងអន្តរជាតិ។ **រដ្ឋមន្ត្រីទាំងពីរ** បានគូសបញ្ជាក់ពីសារសំខាន់នៃការពង្រឹងនូវមជ្ឈភាព និងឯកភាពអាស៊ាន នៅក្នុងការប្រាស្រ័យទាក់ទងជាមួយដៃគូនានា តាមរយៈយន្តការអាស៊ាន ព្រមទាំងបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិកដែលជាមគ្គុទេសក៍ សម្រាប់ការចូលរួមរបស់អាស៊ាន នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងតំបន់មហាសមុទ្រឥណ្ឌាផងដែរ។ **រដ្ឋមន្ត្រីទាំងពីរ** ប្តេជ្ញាពង្រឹងការគាំទ្រទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ។

កិច្ចប្រជុំបានបញ្ចប់ទៅ ដោយការចុះហត្ថលេខាលើកំណត់ហេតុស្តីពីលទ្ធផលកិច្ចប្រជុំ JCBC លើកទី៥។  កិច្ចប្រជុំ JCBC លើកទី៦ នឹងប្រព្រឹត្តទៅនៅប្រទេសឥណ្ឌូណេស៊ី ក្នុងឆ្នាំ ២០២៦។

ក្នុងអំឡុងពេលស្នាក់នៅកម្ពុជា **លោកជំទាវ** Retno L.P. Marsudi បានចូលជួបសម្តែងការគួរសមចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា៕

ថ្ងៃពុធ ២ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤